# ច្បាប់បន្ថែមទីក្រុងម៉ូណាកូ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៦១

## មាតិកា


មាត្រា១ : កម្រៃបន្ថែម

មាត្រា២ : កម្រៃបន្ថែមផ្សេងទៀត

មាត្រា៣ : ការផ្លាស់ប្ដូរបរិមាណនៃកម្រៃ

មាត្រា៤ : មូលនិធិបំរុងទុក ការបែងចែកប្រាក់ចំណូលដែលលើស

មាត្រា៥ : គណនីដោយឡែកចំពោះប្រទេសទាំងឡាយដែលមិនមែនជាភាគីនៃច្បាប់ ឆ្នាំ១៩៣៤ឬច្បាប់ឆ្នាំ១៩៦០

មាត្រា៦ : រយៈពេលកំណត់ដើម្បីចុះហត្ថលេខា ការចូលជាសមាជិក

មាត្រា៧ : ការផ្ដល់សច្ចាប័ន ការចូលជាធរមាន

មាត្រា៨ : ការចុះហត្ថលេខា ច្បាប់ចម្លងដែលបានបញ្ជាក់


## មាត្រា១

១- បន្ថែមលើកម្រៃដែលមានចែងក្នុងមាត្រា១៥ នៃកិច្ចព្រមព្រៀងទីក្រុងឡាអេដែលបានកែប្រែនៅទីក្រុងឡុងដ៍ កម្រៃបន្ថែមខាងក្រោមនេះ ត្រូវបង់ទៅលើប្រតិបត្តិការ ដែលបានបញ្ជាក់ច្បាស់ដូចខាងក្រោមៈ

១. ចំពោះការតម្កល់គំនូរតែមួយ សម្រាប់រយៈពេល៥ឆ្នាំដំបូងៈ ចំនួន ២០(ម្ភៃ) ហ្វ្រង់ស្វីស

២. ចំពោះការតម្កល់គំនូរតែមួយ នៅពេលផុតកាលបរិច្ឆេទរយៈពេលដំបូង ហើយសម្រាប់រយៈពេល១០ឆ្នាំបន្ទាប់ៈ ចំនួន ៤០(សែសិប) ហ្វ្រង់ស្វីស

៣. ចំពោះការតម្កល់គំនូរច្រើន ក្នុងរយៈពេល៥ឆ្នាំដំបូងៈ ចំនួន ៥០(ហាសិប) ហ្វ្រង់ស្វីស

៤. ចំពោះការតម្កល់គំនូរច្រើន នៅពេលផុតរយៈពេលដំបូង ហើយសម្រាប់រយៈពេល១០ឆ្នាំបន្ទាប់ៈ ចំនួន ២០០(ពីររយ) ហ្វ្រង់ស្វីស ។

២- ប្រសិនបើបានបង់កម្រៃដូចបានកំណត់ក្នុងមាត្រា១៥.២ និងមាត្រា១៥.៤ នៃកិច្ចព្រមព្រៀងទីក្រុងឡាអេដែលបានកែប្រែនៅទីក្រុងឡុងដ៍ បន្ទាប់ពីកាលបរិច្ឆេទនៃច្បាប់នេះប៉ុន្តែមុនច្បាប់នេះចូលជាធរមាន ដែលបានកំណត់សម្រាប់រដ្ឋនីមួយៗស្របតាម បទប្បញ្ញត្តិនៃ

កថាខណ្ឌ៧(២) និង ៧(៣) នៅពេលដែលរយៈពេលដំបូងនៃកិច្ចការពារដំបូងត្រូវផុតកំណត់ បន្ទាប់ពីការចូលជាធរមាននេះ បុគ្គលដែលបានតម្កល់ត្រូវបង់កម្រៃបន្ថែមសម្រាប់ការពន្យារពេលដូចបានបញ្ជាក់ក្នុងចំណុច(១)២ និង(១)៤ នៃមាត្រានេះ។ នៅពេលច្បាប់នេះចូលជាធរមាន ការិយាល័យអន្តរជាតិនឹងណែនាំអ្នកតម្កល់ដែលពាក់ព័ន្ធឲ្យបង់កម្រៃបន្ថែម ក្នុងរយៈពេល៦(ប្រាំមួយ)ខែ បន្ទាប់ពីការទទួលបាននូវការជូនដំណឹង ។ ប្រសិនបើមិនបានធ្វើការបង់ប្រាក់ក្នុងរយៈពេលនេះទេ ការពន្យារពេល នឹងត្រូវបានចាត់ទុកជាមោឃៈ ហើយការយោងទៅដល់ការបង់ប្រាក់នោះ ក៏នឹងត្រូវលុបចេញពីបញ្ជីដែរ ។ ក្នុងករណីនេះ កម្រៃនៃការពន្យារពេលដែលបានបង់រួច ត្រូវបានប្រគល់ជូនវិញ។

## មាត្រា២

កម្រៃបន្ថែមចំនួន ២០(ម្ភៃ) ហ្វ្រង់ស្វីស ឬ ចំនួន ១០(ដប់) ហ្វ្រង់ស្វីសក៏ត្រូវបង់ដែរ សំរាប់រាល់ប្រតិបត្តិការផ្សេងទៀត ដែលបានចែងដោយកិច្ចព្រមព្រៀងទីក្រុងឡាអេដែលបានកែប្រែនៅទីក្រុងឡុងដ៍ និងដែលបទបញ្ជានៃកិច្ចព្រមព្រៀងខាងលើកំណត់ កម្រៃឲ្យបង់ ៥ (ប្រាំ) ហ្វ្រង់ស្វីស ឬ ២,៥០(ពីរហ្វ្រង់កន្លះ) ហ្វ្រង់ស្វីស ។

## មាត្រា៣

១- កម្រៃដែលបានកំណត់ក្នុងមាត្រា១ និងមាត្រា២ នៃច្បាប់នេះអាចផ្លាស់ប្តូរតាមសំណើរបស់ការិយាល័យអន្តរជាតិ ឬតាមសំណើរបស់រដ្ឋាភិបាលស្វីសដោយស្របតាមនីតិវិធីដែលបានកំណត់ខាងក្រោម។

២- សំណើនេះត្រូវជូនដំណឹងទៅកាន់ការិយាល័យរបស់រដ្ឋដែលជាភាគីនៃច្បាប់នេះ ហើយរដ្ឋទាំងនោះត្រូវជូនដំណឹងអំពីទស្សនៈរបស់ខ្លួន ទៅកាន់ការិយាល័យអន្តរជាតិក្នុងរយៈពេល៦(ប្រាំមួយ)ខែ ។ បន្ទាប់ពីរយៈពេលនេះ ប្រសិនបើការផ្លាស់ប្តូរកម្រៃ បានអនុម័តដោយសំលេងភាគច្រើននៃការិយាល័យខាងលើដោយមិនមានការជំទាស់ ការផ្លាស់ប្តូរនេះ នឹងចូលជាធរមាននៅថ្ងៃដំបូងនៃខែ បន្ទាប់ពីកាលបរិច្ឆេទនៃការបញ្ជូនសេចក្តីជូនដំណឹងដោយការិយាល័យអន្តរជាតិទៅកាន់ការិយាល័យខាងលើ ។

## មាត្រា៤

១- នឹងត្រូវបង្កើតមូលនិធិបំរុងទុកដែលមិនលើសពី ៥០,០០០(ប្រាំម៉ឺន)ហ្វ្រង់ស្វីស ចេញពីប្រាក់ចំណូលដែលលើស ដែលបានមកពីការអនុវត្តន៍កម្រៃបន្ថែម ។
២- នៅពេលដែលមូលនិធិបំរុងទុកបានកើនដល់ចំនួននេះ ប្រាក់ចំណូលដែលលើសបន្ថែមទៀតត្រូវធ្វើការបែងចែកក្នុងចំណោមរដ្ឋទាំងឡាយដែលជាភាគីនៃច្បាប់នេះ តាមសមាមាត្រទៅនឹងចំនួនគំនូរដែលបានតម្កល់ដោយប្រជាពលរដ្ឋរបស់ខ្លួន ឬបានតម្កល់ដោយបុគ្គលផ្សេងទៀតដូចមានចែងក្នុងមាត្រា១ នៃកិច្ចព្រមព្រៀងទីក្រុងឡាអេដែលបានកែប្រែនៅទីក្រុងឡុងដ៏ ។

## មាត្រា៥

នៅពេលដែលគ្រប់ប្រទេសទាំងអស់ដែលជាសមាជិកនៃសហភាព ដែលបានបង្កើតឡើងដោយកិច្ចព្រមព្រៀងទីក្រុងឡាអេដែលបានកែប្រែនៅទីក្រុងឡុងដ៏ លែងជាភាគីនៃច្បាប់នេះ ឬលែងជាភាគីនៃកិច្ចព្រមព្រៀងទីក្រុងឡាអេចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ ១៩៦០ ការិយាល័យអន្តរជាតិត្រូវរៀបចំគណនីដោយឡែក សម្រាប់ប្រទេសទាំងឡាយដែលជាភាគីនៃច្បាប់នេះ និងសម្រាប់ប្រទេសទាំងឡាយដែលគ្រាន់តែជាភាគីនៃកិច្ចព្រមព្រៀងទីក្រុងឡាអេដែលបានកែប្រែនៅទីក្រុងឡុងដ៏ ។

## មាត្រា៦

១- ច្បាប់នេះនៅតែបើកចំហសម្រាប់ការចុះហត្ថលេខារហូតដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ ១៩៦២ ។
២- ប្រទេសជាសមាជិកនៃកិច្ចព្រមព្រៀងទីក្រុងឡាអេ ដែលបានកែប្រែនៅទីក្រុងឡុងដ៏ដែលមិនបានចុះហត្ថលេខាលើច្បាប់នេះ អាចចូលជាសមាជិកច្បាប់នេះបាន។ ក្នុងករណីនេះ បទប្បញ្ញត្តិនៃមាត្រា១៦និង១៦ស្ទួន នៃអនុសញ្ញាទីក្រុងប៉ារីសស្តីពីកិច្ចការពារកម្មសិទ្ធិឧស្សាហកម្ម ត្រូវយកមកអនុវត្ត។

## មាត្រា៧

១- ច្បាប់នេះត្រូវផ្តល់សច្ចាប័ន ហើយលិខិតតុបករណ៍នៃការផ្តល់សច្ចាប័នត្រូវតម្កល់ជូនរដ្ឋាភិបាលក្សត្របុរីម៉ូណាកូ ។ ការតម្កល់នេះត្រូវជូនដំណឹងដោយរដ្ឋាភិបាលក្សត្របុរីម៉ូណាកូទៅកាន់រដ្ឋាភិបាលនៃសហព័ន្ធស្វីស ។ រដ្ឋាភិបាលនៃសហព័ន្ធស្វីសត្រូវជូនដំណឹងអំពីការតម្កល់ទៅកាន់រដ្ឋហត្ថលេខីទាំងឡាយ ។

២- ច្បាប់នេះត្រូវចូលជាធរមាននៅពេលផុតកំណត់រយៈពេល ១(មួយ) ខែ គិតចាប់ពីកាលបរិច្ឆេទនៃការបញ្ជូនសេចក្តីជូនដំណឹង អំពីការតម្កល់លិខិតតុបករណ៍នៃការផ្តល់សច្ចាប័នទី២ ដោយរដ្ឋាភិបាលនៃសហព័ន្ធស្វីសទៅកាន់រដ្ឋហត្ថលេខីទាំងឡាយ។

៣- ទាក់ទងនឹងរដ្ឋដែលតម្កល់លិខិតតុបករណ៍នៃការផ្តល់សច្ចាប័នរបស់ខ្លួន ក្រោយពីការតម្កល់លិខិតុបករណ៍នៃការផ្តល់សច្ចាប័នទី២ ដូចបានលើកឡើងក្នុងកថាខណ្ឌខាងលើ ច្បាប់នេះត្រូវចូលជាធរមាន នៅពេលផុតកំណត់រយៈពេល១(មួយ)ខែ ដោយគិតចាប់ពីកាលបរិច្ឆេទនៃការបញ្ជូនសេចក្តីជូនដំណឹង អំពីការតម្កល់លិខិតតុបករណ៍នៃការផ្តល់សច្ចាប័នដែលពាក់ព័ន្ធ ដោយរដ្ឋាភិបាលនៃសហព័ន្ធស្វីសទៅកាន់រដ្ឋហត្ថលេខីទាំងឡាយ ។

## មាត្រា៨

ច្បាប់នេះត្រូវចុះហត្ថលេខាជាឯកសារតែមួយ និងត្រូវតម្កល់ទុកក្នុងបណ្ណសារដ្ឋានរបស់រដ្ឋាភិបាលក្សត្របុរីម៉ូណាកូ។ ច្បាប់ចម្លងដែលបានបញ្ជាក់ ត្រូវបញ្ជូនដោយរដ្ឋាភិបាលនៃក្សត្របុរីម៉ូណាកូទៅកាន់រដ្ឋាភិបាលនីមួយៗ នៃប្រទេសទាំងឡាយនៃសហភាពឡាអេ ។